


# ការការពារសុវត្ថិភាពនិងការគាំពារកុមារនៅក្នុង សិក្ខាសាលាក្នុងប្រព័ន្ធអប់រំ

**11th & 12th August 2023**

**Phnom Penh, Cambodia**

សាលាជាច្រើនមិនមានការយល់ដឹង ទេពកោសល្យ ហើយនឹងធនធានដើម្បីឆ្លើយតបទៅនឹងឧប្បទ្ទវហេតុនៃការរំលោភបំពាននិងការកេងប្រវ័ញ្ចលើកុមារប្រកបដោយប្រសិទ្ធភាពដោយសារតែខ្វះការបណ្ដុះបណ្ដាលផ្នែកការគាំពារកុមារនិងការការពារសុវត្ថិភាពកុមារឲ្យបានច្បាស់លាស់

**វាជាបេសកកម្មរបស់ពួកយើង ដើម្បីផ្លាស់ប្ដូររឿងនេះ!**

# សន្និសិទ្ធនេះមានគោលបំណងផ្តល់នូវ៖

**150**

លោកគ្រូទាំងអស់ឲ្យមានមូលដ្ឋានបណ្តុះបណ្តាលការគាំពារកុមារ និងការការពារសុវត្ថិភាពដល់កុមារ

**40**

លោកគ្រូអ្នកគ្រូទាំងអស់ជាមួយនូវទេពកោសល្យដើម្បីបណ្តុះបណ្តាកអ្នកដឹទេក្នុងការការពារសុវត្ថិភាព ឬសង្គ្រោះបឋមផ្នែកផ្លូវចិត្ត

**50**

ថ្នាក់ដឹកនាំក្នុងវិស័យសិក្សាអប់រំជាមួយនឹងទេពកោសល្យកម្រិតខ្ពស់ដើម្បីកាត់បន្ថយ ស្វែងយល់ និងគ្រប់គ្រងការចោទប្រកាន់លើការរំលោភបំពានលើកុមារ

**1000s**

ការគាំពារកុមារទាំងអស់យ៉ាងហោចណាស់នឹងប្រឈមហានិភ័យនៃគ្រោះថ្នាក់ និងការរំលោភបំពានដោយសារគ្រូរបស់ពួកគេ និងមានទេពកោសល្យកម្រិតខ្ពស់

SPONSORED BY:

CPU CHILD PROTECTION UNIT

CAMBODIAN CHILDREN'S FUND

ENCOMPASS Safeguarding



# សូមស្វាគមន៍មកកាន់សិក្ខាសាលាសិក្សាអប់រំនៃការ ការពារសុវត្ថិភាពនិងការគាំពារកុមារ

នៅក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យនេះជាដំបូងបង្អស់នៅក្នុងប្រទេសកម្ពុជា និងបង្ហាញនូវមូលដ្ឋានគ្រឹះសម្រាប់អនាគតនៃការគាំពារកុមារនៅក្នុងសាលាសម្រាប់ជំនាន់ខាងមុខ។ កុមារទាំងអស់សមនឹងទទួលបានសុវត្ថិភាព និងបរិយាកាសនៃការចិញ្ចឹមបីបាច់ដើម្បីឲ្យការលូតលាស់។ សិក្ខាសាលានេះមានគោលបំណងដាក់អំណាចទៅក្នុងដៃទាំងគូរបស់លោកអ្នកដើម្បីការពារនិងទប់ស្កាត់ការកេងប្រវ័ញ្ចឬការរំលោភបំពានលើកុមារដែលស្ថិតនៅក្រោមការថែទាំរបស់លោកអ្នក។

បំពាក់ដល់គ្រូនិងថ្នាក់ដឹកនាំការសិក្សាអប់រំទាំងអស់នូវចំណេះដឹង និងទេព្យកោសល្យផ្សេងៗ ដើម្បីគ្រប់គ្រងនិងឆ្លើយតបទៅនឹងការគម្រាមកំហែងដល់សុខមាលភាពកុមារគឺជាការគាំពារជួរមុខដើម្បីការពារតម្លៃរបស់កុមារ។

យើងទាំងអស់គ្នាក៏ត្រូវការធានាផងដែរថាកុមាររងគ្រោះទាំងអស់ត្រូវបានផ្តល់នូវការគាំទ្រដ៏សមរម្យដែលពួកគេត្រូវការនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ វគ្គបណ្តុះបណ្តាលនេះនឹងបង្កើនបន្ថែមដល់នគរបាលជាតិកម្ពុជា និងមន្ត្រីគាំពារកុមារនូវបច្ចេកទេសដើម្បីដោះស្រាយសំណុំរឿងដ៏រសើបនិងការយកចិត្តទុកដាក់ដែលធ្វើឲ្យដំណើរការមានការប៉ះទង្គិចតិចតួចដល់កុមារដែលមានការរំលោភបំពាន។ ខ្ញុំមានសេចក្តីរីករាយចំពោះលោកអ្នកទាំងអស់គ្នាដែលបានជួយសម្របសម្រួលក្នុងការបណ្តុះបណ្តាលក្នុងសិក្ខាសាលានេះ។ សូមថ្លែងអំណរគុណដល់គ្រូឧទ្ទេសនាមរបស់ពួកយើងទាំងអស់គ្នាដែលយល់ព្រមចែករំលែកនូវជំនាញរបស់អស់លោកនិងលោកស្រី។

ហើយនឹងការកោតសសើរជាពិសេសដល់លោក **James McCabe** ដែលជានាយកប្រតិបត្តិសម្រាប់អង្គភាពការពារកុមាររបស់ពួកយើងហើយនិងលោក **Nick Rose** ជានាយកប្រតិបត្តិរងនៃអង្គភាពការពារកុមារ នូវការប្តេជ្ញាចិត្តរបស់ពួកគាត់ដើម្បីធ្វើឲ្យមានសិក្ខាសាលានេះកើតឡើង ហើយនឹងបន្តការលះបង់របស់ពួកគាត់ដើម្បីការពារនិងបម្រើកុមារកម្ពុជា។

ការរួមចំណែករបស់យើងទាំងអស់គ្នា ធ្វើឲ្យមានការផ្លាស់ប្តូរ។

**Scott Neeson**
ស្ថាបនិករបស់អង្គការមូលនិធិកុមារកម្ពុជា

**SPONSORED BY:**

CPU CHILD PROTECTION UNIT

CAMBODIAN CHILDREN'S FUND

ENCOMPASS Safeguarding

# ប្រវត្តិគ្រូឧទ្ទេសនាម



## Sian Jorgensen

**BA (Hons), MA, MSc, MBASW, MBACP**

**Sian** មានលក្ខណៈសម្បត្តិខ្ពស់ និងមានបទពិសោធន៍ធ្វើជាគ្រូបង្វឹកនិងទីប្រឹក្សាផ្នែកការការពារសុវត្ថិភាពជាអន្តរជាតិមានសញ្ញាបត្រអនុបណ្ឌិតផ្នែកប្រឹក្សាយោបល់និងកិច្ចការសង្គម ដែលមានបទពិសោធន៍ការងារជាអន្តរជាតិជាង ២០ឆ្នាំ និងការងារភាគច្រើនជាមួយសាលាអន្តរជាតិ។

គាត់បានបញ្ចូលបទពិសោធន៍របស់គាត់ផ្នែកស៊ើបអង្កេត ជាអន្តរជាតិគួរឲ្យចាប់អារម្មណ៍ និងចំណេះដឹងនៃការរំលោភបំពានលើកុមារជាមួយនឹងមនុស្សសំខាន់ៗ ការផ្តល់ព័ត៌មានទាក់ទងនឹងការរងគ្រោះ និងការស្តារឡើងវិញនូវការអនុវត្តប្រឹក្សាយោបល់។ **Sian** គឺជាមនុស្សដែលមានចំណាប់ចំណូលចិត្តអំពីការការពារកុមារពីការរំលោភបំពាន និងរងការប៉ះទង្គិចផ្លូវចិត្តរយៈពេលវែង។



## Aylssa Cowell

**DIPCYW, MA, MED,**

*សមាជិកសមាគមប្រឹក្សាយោបល់របស់ប្រទេសអូស្ត្រាលី*

**Alyssa** គឺជាស្ថាបនិកនៃ **7 North Education** ដែលផ្តល់ការបណ្តុះបណ្តាលនិងសេវាកម្មប្រឹក្សាយោបល់ផ្នែកគុណធម៌ក្នុងសាលា ទៅដល់សាលាអន្តរជាតិទូទាំងទ្វីបអាស៊ី

គាត់មានជំនាញនៅក្នុងការបណ្តុះបណ្តាលសង្គ្រោះបឋមផ្នែកផ្លូវចិត្ត ហើយនិងការចែករំលែកការយល់ដឹងជុំវិញការឆ្លើយតបទៅនឹងការរំលោភបំពានពីរដៃគូនៅក្នុងសាលា។

**SPONSORED BY:**

CPU CHILD PROTECTION UNIT

CAMBODIAN CHILDREN'S FUND

ENCOMPASS Safeguarding

# ប្រវត្តិគ្រូឧទ្ទេសនាម



## Nick Rose

**MA (Emerg Mngt), MA (L&M Policing)**

បន្ថែមលើករណីកិច្ចរបស់គាត់ជានាយករងរបស់ អង្គភាពការពារកុមារ (CPU) លោក Nick ក៏បានគ្រប់គ្រងអង្គភាពឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតប្រឆាំងនឹងកុមារ។ សាវតាររបស់គាត់គឺធ្វើការជាប៉ូលីសនៅថ្នាក់រដ្ឋនិងសហព័ន្ធក្នុងប្រទេសអូស្ត្រាលី និងអាស៊ីអាគ្នេយ៍។ ហើយបច្ចុប្បន្ននេះ គាត់ជាអ្នកបណ្តុះបណ្តាលនិងផ្តល់ដំបូន្មានដល់នគរបាលជាតិកម្ពុជាក្នុងការស៊ើបអង្កេតបទឧក្រិដ្ឋព្រហ្មទណ្ឌប្រឆាំងនឹងកុមារ។

វិស័យដ៏ទៃទៀតរបស់គាត់គឺផ្តោតទៅលើ កុសលវិច្ឆ័យតាមប្រព័ន្ធឌីជីថល ការស៊ើបអង្កេតកន្លែងកើតហេតុនៃបទឧក្រិដ្ឋប្រកបដោយគ្រោះថ្នាក់ និងសុវត្ថិភាពរបស់មន្ត្រី។ គាត់មានការប្តេជ្ញាចិត្តក្នុងការការពារកុមារ ពីការរំលោភបំពាននិងការធានាឲ្យបានថាការបង្កគ្រោះថ្នាក់ដល់កុមារទាំងអស់ត្រូវបានបញ្ឈប់។

---



## Prof. Becky Milne

**PhD, CPsychol, CSci, AFBPsS**

Beckey គឺជាសាស្ត្រាចារ្យដ៏ល្បីល្បាញកម្រិតអន្តរជាតិ ស្តីពីការធ្វើកោសល្យវិច្ឆ័យលើចិត្តវិទ្យា ដែលធ្វើការយ៉ាងចិត្តស្និទ្ធជាមួយទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌផ្សេងៗជុំវិញពិភពលោក ទាក់ទងទៅនឹងការយល់ដឹងនៃបច្ចេកទេសសម្ភាសន៍ ហើយនិងការសម្ភាសន៍ជនរងគ្រោះនិងការសម្ភាសន៍សាក្សី។

Becky ក៏ជាមនុស្សម្នាក់យ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ស្នាដៃមគ្គុទ្ទេសនៃការប្រមូលភស្តុតាងថ្នាក់ជាតិដ៏ល្អបំផុតនៅក្នុងចក្រភពអង់គ្លេស ចំពោះការសម្ភាសន៍កុមារដែលងាយរងគ្រោះ និងរងការបំភិតបំភ័យហើយនិងសាក្សីពេញវ័យនិងជនរងគ្រោះដែលត្រូវបានការរំលោភបំពាន។

SPONSORED BY:

CPU CHILD PROTECTION UNIT · CAMBODIAN CHILDREN'S FUND · ENCOMPASS Safeguarding

# ប្រវត្តិគ្រូឧទ្ទេសនាម



## Nigel Lee

**COS, MSc, PGC LTHE, FHEA**

**Nigle** គឺជាសាស្ត្រាចារ្យជាន់ខ្ពស់ផ្នែកឧក្រិដ្ឋវិទ្យាដែលបានចូលនិវត្តន៍ ពីការងារស៊ើបអង្កេតរបស់គាត់អស់រយៈពេល ២៥ ឆ្នាំ។ គាត់មានបទពិសោធន៍រយៈពេល ១៥ ឆ្នាំក្នុងការស៊ើបអង្កេតលើការរំលោភបំពានលើកុមារ។ ហើយគាត់ក៏ធ្លាប់ទទួលបានការបណ្តុះបណ្តាលកម្រិតខ្ពស់ដែលមាននៅក្នុងចក្រភពអង់គ្លេស ស្តីដីអំពីការសម្ភាសន៍ជនសង្ស័យ និងការសម្ភាសន៍ជនរងគ្រោះដែលភាពទន់ខ្សោយ។

គាត់ធ្លាប់បានរួមចំណែកជាមួយនឹងការសរសេរ និងផ្តល់ការបណ្តុះបណ្តាលដល់អង្គភាព **(CPU)** និងនរគលបាលជាតិកម្ពុជា **(CNP)** នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០១៣ ។



## Mark Fower

**BSc (Hons)**

**Mark** គឺបានចូលនិវត្តន៍ពីការងារជាភ្នាក់ងារស៊ើបអង្កេតរបស់គាត់ដែលមានបទពិសោធន៍រយៈពេល ៣០ ឆ្នាំ ភាគច្រើននៅក្នុងផ្នែកឧក្រិដ្ឋកម្មផ្លូវភេទប្រឆាំងនឹងមនុស្សពេញវ័យនិងកុមារ។

គាត់បានបង្កើតនិងប្រគល់នូវកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីនគរបាលក្នុងការទទួលបានភស្តុតាងដ៏ល្អបំផុត ដើម្បីបង្កើនការប្រមូលភស្តុតាងពីកុមារនិងមនុស្សពេញវ័យដែលទន់ខ្សោយ។

គាត់បានចូលរួមការបណ្តុះបណ្តាលជាមួយនឹងអង្គភាពការពារកុមារ (CPU) ចាប់តាំងឆ្នាំ ២០១៧ ។

**SPONSORED BY:**

CPU CHILD PROTECTION UNIT

CAMBODIAN CHILDREN'S FUND

ENCOMPASS Safeguarding




## James McCabe

### នាយកប្រតិបត្តិអង្គភាពការពារកុមារ

លោក **James** បានចំណាយពេលវេលាអស់រយៈពេល ២០ឆ្នាំ ក្នុងការអនុវត្តច្បាប់, ថ្នាក់ជាតិ, និងថ្នាក់អន្តរជាតិ។ លោក **James** មានលក្ខណៈសម្បត្តិជារង្វូអាជ្ញាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងជាមន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ហើយនិងជាអ្នកមើលការខុសត្រូវលើការស៊ើបអង្កេត និងប្រតិបត្តិការរបស់អង្គភាពការពារកុមារទាំងមូល។

លោក **James** បានត្រឡប់មកប្រទេសកម្ពុជាវិញនៅក្នុងឆ្នាំ ២០១២ ទីនោះហើយដែលគាត់បានបង្កើតទស្សនៈទាននៃអង្គភាពការពារកុមារ **(CPU)** ជាមួយនឹងការណែនាំរបស់លោក **Scott Neeson** ហើយនិងមានការគាំទ្រឲ្យបង្កើតអង្គភាពនេះឡើងយ៉ាងពិតប្រាកដ។ លោក **James** បានធ្វើការស៊ើបអង្កេតនិងសម្របសម្រួលការស៊ើបអង្កេតក្នុងឧក្រិដ្ឋកម្មប្រឆាំងនិងកុមារចាប់តាំងពីឆ្នាំ ២០១២ មកដល់ពេលបច្ចុប្បន្ន។

ឧក្រិដ្ឋកម្មទាំងនោះរួមមានមនុស្សឃាត ការរំលោភបំពានផ្លូវភេទ, ការជួញដូរកុមារ, ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត និងគ្រប់ទម្រង់នៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរតម្រូវឲ្យមានការឆ្លើយតបពីអ្នកជំនាញនិងអ្នកសម្របសម្រួលការស៊ើបអង្កេត ហើយនិងការគាំទ្រពីគ្រប់ទីភ្នាក់ងារទាំងអស់។ ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ អង្គភាពការពារកុមារបានបង្ហាញម្តងហើយម្តងទៀត នូវប្រសិទ្ធភាពនៃដំណើរការសហប្រតិបត្តិការ។ ទស្សនៈទានដំបូងនៃភាពជាដៃគូរវាងអតីតប៉ូលីសអន្តរជាតិ បទពិសោធន៍ក្នុងនីតិវិធីស៊ើបអង្កេតបែបទំនើប ហើយនិងការប្តេជ្ញាចិត្តរបស់មន្ត្រីនគរបាលជាតិកម្ពុជាបាននាំមកនូវលទ្ធផលជាទីកត់សម្គាល់។

ប្រសិនបើយើងប្រៀបធៀបនៅក្នុងទម្រង់នៃអត្រានៃការចាប់ខ្លួនអត្រា នៃការកាត់ទោស ការណែនាំភស្តុតាងកោសល្យវិច្ច័យ ការបណ្តុះបណ្តាលមន្ត្រីនគរបាល ឬក៏ការផ្តល់ការថៃទាំដល់កុមាររងគ្រោះអង្គភាពការពារកុមារ **(CPU)** បានសម្រេចលទ្ធផលដ៏ច្រើនលើសលប់លើសពីការរំពឹងទុក។

គ្មានកិត្តិយស ឬការទទួលខុសត្រូវណាមួយដែលសំខាន់ជាងការការពារបុគ្គលទាំងឡាយណាដែលមិនអាចការពារខ្លួនឯងបាននោះទេ "នោះគឺកុមារ" ។

## សេចក្តីសង្ខេបសិក្ខាសាលាក្នុងប្រព័ន្ធអប់រំស្តីពីការគាំពារកុមារ និងផ្តល់សុវត្ថិភាពកុមារ

- សិក្ខាសាលារយៈពេល ២ថ្ងៃនេះគឺចងក្រងឡើងដើម្បី បញ្ជាក់នូវតម្រូវការដល់ការចែករំលែកនៃការយល់ដឹង នូវករណីកិច្ចរបស់លោកគ្រូអ្នកគ្រូទាំងអស់ក្នុងការថែទាំកុមារដោយបន្ថែមថ្ងៃលើការបណ្តុះបណ្តាលគ្រូបង្គោល។
- នាំមកនូវជាមួយអ្នកជំនាញ មកកាន់ប្រទេសកម្ពុជាដើម្បីផ្តល់ការបណ្តុះបណ្តាលដែលមានគុណភាព និងចំណេះដឹងខ្ពស់។
- ដើម្បីគាំទ្រដល់ថ្នាក់ដឹកនាំការការពារសុវត្ថិភាពនៅក្នុងសាលាជាតិនិងអន្តរជាតិ ស្តីអំពីសារៈសំខាន់នៃការយល់ដឹងនូវគ្រោះថ្នាក់ និងបង្កើតដំណើរការឲ្យច្បាស់លាស់មួយដើម្បីរាយការណ៍ និងស្វែងយល់ពីការព្រួយបារម្ភក្នុងការគាំពារកុមារ។
- ដើម្បីបង្កើនការយល់ដឹងនៅលើវិស័យផ្សេងៗដូចជា: ឥរិយាបថបង្ករគ្រោះថ្នាក់ផ្លូវភេទ ត្រួតត្រាដោយបង្ខំលើទំនក់ទំនាក់ទំនងនៃការលួងលោម ការរំលោភបំពានតាមប្រព័ន្ធអនឡាញនិងការគាំទ្រដល់ជនរងគ្រោះពីការរំលោភបំពាន។

---

## មាតិកានៃសិក្ខាសាលា

| ថ្ងៃសុក្រ ១២ សីហា<br>សិក្ខាសាលាថ្ងៃទី១ | ថ្ងៃសៅរ៍ ១២ សីហា<br>សិក្ខាសាលាថ្ងៃទី២ |
|---|---|
| **ពិធីបើកវគ្គ**<br>• សន្ទរកថារបស់អ្នកស្រី **Sian Jorgensen** និង លោក **Nick Rose**<br>• យល់ដឹងពីសន្ធិសញ្ញាស្តីពីសិទ្ធិរបស់កុមរ។ ស្វែងយល់ពីកាតព្វកិច្ចថែទាំរបស់គ្រូបង្រៀនក្នុងភាពជាដៃគូជាមួយ និងមន្ត្រីនគរបាល។<br>• កម្រិត១ បណ្តុះបណ្តាការការពារសុវត្ថិភាពដល់គ្រូបង្រៀន<br>• ការជួបជុំគ្នាក្នុងការទទួលទានភេជ្ជៈ ដើម្បីបង្កើតបណ្តាញទំនាក់ទំនង<br>* សម្រាប់តែអ្នកមានការអញ្ជើញតែប៉ុណ្ណោះ! | **សិក្ខាសាលា**<br>• បង្កើតសុវត្ថិភាពក្នុងសាលា-ជាប្រព័ន្ធ, រាយការណ៍និងជាបណ្តុះបណ្តាល<br>• ការឆ្លើយតបទៅនឹងកុមារដែលបានរងគ្រោះ<br>• ការរំលោភបំពានផ្លូវភេទលើកុមារតើអ្នកណាគឺជាអ្នករំលោភហើយតើពួកគេបង្ខំកុមារដោយរបៀបណា<br>• ឥរិយាបថបង្កគ្រោះថ្នាក់ផ្លូវភេទពីដៃគូ និងការយល់ព្រម<br>• ទេពកោសល្យសម្ភាសន៍ជាមូលដ្ឋាន។<br>**សំណួរនិងចម្លើយជាមួយនឹងគ្រូឧទ្ទេសនាមទាំងស្រុង**<br>**បិទវគ្គបណ្តុះបណ្តាល** |

**SPONSORED BY:**

CPU CHILD PROTECTION UNIT — CAMBODIAN CHILDREN'S FUND — ENCOMPASS Safeguarding

# កាលវិភាគថ្ងៃទី១ -ថ្ងៃសុក្រ ទី ១១ សីហា

| ម៉ោង | សកម្មភាព | ពិស្តារ |
|---|---|---|
| **07:00 – 08:00** | សិក្ខាកាមមកដល់ ចុះឈ្មោះ | តារាងចុះហត្ថលេខាចូល / ហត្ថលេខាតាមឌីជីថលឃ្សែកូង **lanyards** និងរបៀបវារៈសិក្ខាកាមទាំងអស់ |
| **08:00 – 08:10** | កិច្ចស្វាគមន៍សិក្ខាកាមទាំងអស់ | |
| **08:10 – 08:15** | គោរពភ្លេងជាតិ | |
| **08:15 – 08:35** | សុន្ទរកថាបើកវគ្គដោយ កសអ | |
| **08:35 – 08:45** | សុន្ទរកាថាបើកវគ្គដោយ CPU | |
| **08:45 – 08:55** | វគ្គថតរូប | |
| **09:00 – 10:00** | កំណត់សម្គាល់សំខាន់ៗ | វិធីដែលព្រឹត្តិការណ៍នេះបានមកចូលរួមទាំងអស់គ្នា ចក្ខុវិស័យ និងអនាគត |
| **10:00 – 10:30** | តែពេលព្រឹក | |
| **10:30 – 12:00** | ការការពារសុវត្ថិភាពក្នុងប្រទេសកម្ពុជា | ស្វែងយល់បរិបទនៃប្រទេសកម្ពុជា និងសន្ធិសញ្ញាស្តីពីសិទ្ធិកុមារ។ ស្វែងរកលោកគ្រូអ្នកគ្រូ កាតព្វកិច្ចនៃថែទាំក្នុងភាពជាដៃគូជាមួយមន្ត្រីនគរបាល |
| **12:00 – 13:00** | អាហារថ្ងៃត្រង់ | អាហារថ្ងៃត្រង់ **Buffet** - នៅភោជនីយដ្ឋានសណ្ឋាគារកាំបូឌីយ៉ាណា |
| **13:00 – 14:30** | ក្រុមទាំងមូល កម្រិត ១ បណ្តុះបណ្តាលលើវិធានការសុវត្ថភាព ផ្នែកទី ១ | ការរៀបចំសញ្ញាបត្រឲ្យក្រុមទាំងមូល |
| **14:30 – 15:00** | តែថ្ងៃត្រង់ | |
| **15:00 – 16:30** | ក្រុមទាំងមូល កម្រិត ១ បណ្តុះបណ្តាលលើវិធានការសុវត្ថភាព ផ្នែកទី ២ | តម្រូវឲ្យចូលរួមក្នុវគ្គសិក្សាទាំងពីរ |
| **16:30** | បញ្ចប់វគ្គថ្ងៃទី១ - សិក្ខាកាមចាកចេញ | |
| **18:00 – 19:30** | ការជួបជុំគ្នាក្នុងការទទួលទានភេជ្ជៈដើម្បីបង្កើតបណ្តាញទំនាក់ទំនង (ដោយមានការអញ្ជើញ) | |

**SPONSORED BY:**

CPU CHILD PROTECTION UNIT

CAMBODIAN CHILDREN'S FUND

ENCOMPASS Safeguarding

# កាលវិភាគថ្ងៃទី២ -ថ្ងៃសៅរ៍ ទី ១២ សីហា

| ម៉ោង | សកម្មភាព | ពិស្តារ |
| --- | --- | --- |
| **07:45 – 08:15** | សិក្ខាកាមមកដល់ | |
| **08:15 – 09:30** | វគ្គ១ **(Group A)** | ការបង្កើតសុវត្ថិភាពក្នុងសាលា - ជាប្រព័ន្ធ, ជារបាយការណ៍និងជាការបណ្តុះបណ្តាល |
| | វគ្គ១ **(Group B)** | ការឆ្លើយតបទៅនិងកុមារដែលរងគ្រោះ |
| **09:30 – 10:00** | តែពេលព្រឹក | |
| **10:00 – 11:15** | វគ្គ២ **(Group A)** | ការឆ្លើយតបទៅនិងកុមារដែលរងគ្រោះ |
| | វគ្គ២ **(Group B)** | ***CSE*** - តើអ្នកណាជាអ្នករំលោភបំពាន និងតើគេបង្ខំកុមារយ៉ាងដូចម្តេច**?** មានការយល់ព្រម |
| **11:15 - 12:30** | វគ្គ៣ **(Group A)** | **CSE** - តើអ្នកណាជាអ្នករំលោភបំពានលើកុមារ និងតើគេបង្ខំកុមារយ៉ាងដូចម្តេច**?** មានការយល់ព្រម |
| | វគ្គ៣ **(Group B)** | អាកប្បកិរិយាបង្ករគ្រោះថ្នាក់ផ្លូវភេទ និងការយល់ព្រមពីដៃគូ |
| **12:30 – 13:30** | អាហារថ្ងៃត្រង់ **Buffet** - នៅភោជនីយដ្ឋានសណ្ឋាគារកាំបូឌីយ៉ាណា | |
| **13:30 – 14:45** | វគ្គ៤ **(Group A)** | អាកប្បកិរិយាបង្ករគ្រោះថ្នាក់ផ្លូវភេទ និងការយល់ព្រមពីដៃគូ |
| | វគ្គ៤ **(Group B)** | ការបង្កើតសុវត្ថិភាពក្នុងសាលា - ជាប្រព័ន្ធ, ជារបាយការណ៍ និងជាការបណ្តុះបណ្តាល |
| **14:45 - 16:00** | មូលដ្ឋាននៃទេពកោសល្យក្នុងការសម្ភាសន៍ | |
| **16:00 - 16:30** | តែពេលថ្ងៃត្រង់ | |
| **16:00 - 17:00** | វគ្គសំណួរនិងចម្លើយ | |
| **17:00 - 17:30** | បិទវគ្គបណ្តុះបណ្តាល | |

**SPONSORED BY:**

CPU CHILD PROTECTION UNIT

CAMBODIAN CHILDREN'S FUND

ENCOMPASS Safeguarding

# ការងារផ្សេងៗរបស់ (CPU) នាពេលបច្ចុប្បន្ន

# វគ្គបណ្តុះបណ្តាលគ្រូបង្គោល 10 សីហា

**Group A** កម្រិត១ គ្រូបង្គោលក្នុងការការពារសុវត្ថិភាពដែលមានលិខិតបញ្ជាក់

គោលបំណង៖ ដើម្បីផ្តល់ដល់សិក្ខាកាមទាំងអស់ នៅការយល់ដឹងស៊ីជម្រៅ នៅអ្វីដែលចាំបាច់ត្រូវបង្រៀននៅក្នុងកម្រិត១ ការបណ្តុះបណ្តាលនៃការការពារសុវត្ថិភាពនិងការផ្តល់ឲ្យពួកគេជាមួយនឹងបទពិសោធន៍ ក្នុងវគ្គ ១ ពិតៗ ដើម្បីជាផ្ទាលនៃចំណេះដឹង។

ដើម្បីបណ្តុះគំនិតសម្រាប់ថ្នាក់ដឹកនាំការការពារសុវត្ថិភាពដែលទើបតែងតាំងថ្មីអ្នកគ្រប់គ្រងធនធានមនុស្ស ប្រធានសន្តិសុខ អ្នកប្រឹក្សយោបយោបល់ជាដើម។

**Group B** គ្រូបង្គោលដែលមានលិខិតបញ្ជាក់លើការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត

គោលបំណង: ដើម្បីផ្តល់ដល់សិក្ខាកាមទាំងអស់នូវចំណេះដឹង និងទេពកោសល្យក្នុងការគាំទ្រដល់សិស្សានុសិស្សដែលអាចមានបទពិសោធន៍ក្នុងការប៉ះទង្គិចផ្លូវចិត្ត ឬការរំលោភបំពាន ឬកំពុងតែតស៊ូជាមួយនឹងអារម្មណ៍ផ្លូវចិត្តរបស់ពួកគេ ដើម្បីសិក្សានៅវិធីសាស្ត្រក្នុងការកំណត់សញ្ញាសម្គាល់និងផ្តល់កញ្ចប់ឧបករណ៍យកទៅប្រើប្រាស់ជាមួយសិស្សានុសិស្សទាំងអស់។

បណ្តុះគំនិតដល់ថ្នាក់ដឹកនាំផ្នែកស្រុកមាលភាព ប្រធានប្រចាំឆ្នាំ អ្នកដឹកនាំប្រចាំថ្នាក់ និងអ្នកប្រឹក្សាយោបល់ដែលមានបទពិសោធន៍តិច។

មេរៀននៃការបណ្តុះបណ្តាលគ្រូបង្គោលផ្តល់នូវគន្លឹះសំខាន់ៗដល់ក្រុមដែលមានការប្តេជ្ញាចិត្តក្នុងវិជ្ជាជីវៈដែលរស់នៅនិងធ្វើការនៅក្នុងប្រទេសកម្ពុជា នូវទេពកោសល្យនិងឧបករណ៍សម្រាប់បណ្តុះបណ្តាលអ្នកផ្សេងទៀតទាំងភាសាខ្មែរនិងអង់គ្លេស។ មេរៀននេះនឹងធានាថាគោលបំណងនៃការការពារកុមារពី គ្រោះថ្នាក់នឹងមិនបញ្ឈប់ក្រោយសិក្ខាសាលានេះទេប៉ុន្តែវានឹងពង្រីកនិងលាតត្រដាងទៅតាមតំបន់។

# ការសម្ភាសន៍កុមារប្រកបដោយមិត្តភាព

- មេរៀននេះមានរយៈពេល ៥ថ្ងៃ/ មានគ្នា ២០-២៤ នាក់ត្រូវបានបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ដែលមានការសម្ភាន៍ប្រកបដោយស្តង់ដារអន្តរជាតិ
- ចង្អុលបង្ហាញដល់នគរបាលជាតិកម្ពុជា **(CNP)** និងមន្ត្រីគាំពារកុមារ មន្ត្រីអនុវត្តន៍ច្បាប់ជួរមុខនិងការតស៊ូមតិដល់ជនរងគ្រោះ។
- ការបង្រៀនរបស់អ្នកជំនាញត្រូវបានផ្តល់ជូនដោយសាស្ត្រាចារ្យទស្សនៈកិច្ចអន្តរជាតិចំនួន ៣ នាក់។
- ពាក្យផ្តាំផ្ញើក្នុងវគ្គបណ្តុះបណ្តាលធ្វើឡើងសម្រាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ច្បាប់និងវប្បធម៌នៅក្នុងប្រទេសកម្ពុជាដែលផ្អែកលើការអនុវត្តល្អបំផុតថ្នាក់អន្តរជាតិត្រូវបានផ្តល់ជូនដោយអ្នកជំនាញនៅក្នុងវិស័យរបស់ពួកគេ។

# សូមថ្លែងអំណរគុណដល់អ្នកឧបត្ថម្ភប្រកបដោយសប្បុរសធម៌

ROYAL GROUP

HOTEL CAMBODIANA

EAST-WEST INTERNATIONAL SCHOOL – PRIDE IN EDUCATION

SOUTHBRIDGE INTERNATIONAL SCHOOL CAMBODIA

Australian College of Professionals

Asian Hope – TODAY • TOMORROW • ETERNITY

AUSTRALIAN INTERNATIONAL SCHOOL PHNOM PENH

The King's School Canterbury – VATTANAC VILLE

SOLENT UNIVERSITY SOUTHAMPTON

ezecom ឈានមុខជានិច្ច

7 education

SPONSORED BY:
SPONSORED BY:

CPU CHILD PROTECTION UNIT

CAMBODIAN CHILDREN'S FUND

ENCOMPASS Safeguarding

# ព័ត៌មានបន្ថែម៖

- ស្វែងយល់បន្ថែមពីអង្គការមូលនិធិកុមារកម្ពុជា (CCF) និងបេសកកម្មរបស់អង្គការតាមរយៈគេហទំព័រ។ [www.cambodianchildrensfund.org](www.cambodianchildrensfund.org)

- ដើម្បីស្វែងយល់បន្ថែមលើអង្គភាពការពារកុមារ (CPU) និងការងារសំខាន់ៗរបស់អង្គភាពសូមចូលមើលក្នុងគេហទំព័រ។ [www.childprotectionunit.org](www.childprotectionunit.org)

- សម្រាប់ការ ប្រឹក្សាយោបល់លើការការពារសុវត្ថិភាពការបណ្តុះបណ្តាលនិងការគាំទ្រសូមចូលមើលក្នុងគេហទំព័រ។
  www.encompass-safeguarding.com or email sian.jorgensen@encompass-safeguarding.com

- សម្រាប់ដំបូន្មាននិងការគាំទ្រជុំវិញបុគ្គលិកសិស្សានុសិស្សការអប់រំសុខភាពនិងសង្គមសូមចូលមើល
  https://7north.education or email hello@7north.education

SPONSORED BY:

CPU CHILD PROTECTION UNIT — CAMBODIAN CHILDREN'S FUND — ENCOMPASS Safeguarding



**SPONSORED BY:**

CPU CHILD PROTECTION UNIT

CAMBODIAN CHILDREN'S FUND

ENCOMPASS Safeguarding